# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៦-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៤២ ស្តីពីការតែងតាំងលោក **គឹម គៅ** ជាឧកញ៉ា ៣៣៤៦

២៦-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៤៣ ស្តីពីការតម្លើងឋានៈឯកឧត្តម **ឌុល គឿន** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រីបន្ថែមលើមុខងារបច្ចុប្បន្ន ៣៣៤៧

២៦-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៤៤ ស្តីពីការតែងតាំងឯកឧត្តម **ទិន យន** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រីបន្ថែមលើមុខងារបច្ចុប្បន្ន ៣៣៤៨

២៦-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៤៥ ស្តីពីការតែងតាំងឯកឧត្តម **ទូច ហេង** ជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៣៣៤៩

២៦-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៤៦ ស្តីពីការតែងតាំងឯកឧត្តម **វង សូត** ជារដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនួសឯកឧត្តម **ញៀប ប៊ុនជិន** ដែលត្រូវផ្លាស់ចេញពីមុខតំណែង ៣៣៥០


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


២៩-៥-២០០៦ -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ៣៣៥១

២៩-៥-២០០៦ -អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានផ្ទៃក្នុង នៃក្រសួងធនធានទឹក និងឧតុនិយម ៣៤១៣

៣០-៥-២០០៦ -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ៣៤១៥

២៩-៥-២០០៦ -អនុក្រឹត្យលេខ ៣៦៩ អនក្រ.តត ស្តីពីការតែងតាំងបន្ថែម គណៈគ្រប់គ្រងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ៣៤១៨

២៩-៥-២០០៦ -អនុក្រឹត្យលេខ ៣៧០ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ៣៤២០

៣០-៥-២០០៦ -អនុក្រឹត្យលេខ ៣៧១ អនក្រ.តត ស្តីពីការសម្រួលភារកិច្ចមន្ត្រីរាជការ ៣៤២១

៣០-៥-២០០៦ -អនុក្រឹត្យលេខ ៣៧២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៤២៣

៣១-៥-២០០៦ -អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ៣៤២៤

## ២-សេចក្តីសំរេច

២៩-៥-២០០៦ -សេចក្តីសំរេចលេខ ២២សសរស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយ និង សម្របសម្រួលករណីក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម **អ៊ុក ឃុន** តាមខ្លឹមសារ នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ៣៤២៥

## III-ការិយាល័យរបស់ក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

៣០-៥-២០០៦ -ប្រកាសលេខ ១២៧ បទ ប្រក ស្តីពីការបង្កើតក្រុមការងារ ដើម្បីរៀបចំអនុវត្ត ឱ្យមាន ប្រសិទ្ធភាព នៃគំរោងប្រាក់កម្ចី (*JBIC*) ៣៤២៧

## ២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១២-៤-២០០៦ -លិខិតលេខ ១០៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អុកតូពុស (ខេមបូឌា) អ៊ិនវេសមេន គ្រុប** ៣៤៣១

២០-៤-២០០៦ -លិខិតលេខ ១០៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី ធី ប៊ី អ៊ិនវេសមេន ខប** ៣៤៣៥

២០-៤-២០០៦ -លិខិតលេខ ១០៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រស្មី មហាសម្បត្តិ** ៣៤៣៧

២០-៤-២០០៦ -លិខិតលេខ ១០៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សូបស៍ (ខេមបូឌា) អិលធីឌី** ៣៤៣៩

២០-៤-២០០៦ -លិខិតលេខ ១០៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីមភៀរៀល ស៊ុយប៉្រីធី ស៊ីវីស** ៣៤៤១

២០-៤-២០០៦ -លិខិតលេខ ១០៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វី យូ អេនធើប្រាយ** ៣៤៤៣

១០-៤-២០០៦ -លិខិតលេខ ១០៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហូលីដេ ស៊ី អេស គ្រុប** ៣៤៤៥

២០-៤-២០០៦ -លិខិតលេខ ១០៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្លូបិល ម៉ារីន អឹស៊ីស** ៣៤៤៧

២៤-៤-២០០៦ -លិខិតលេខ ១០៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិមតីធីស៊ី~ម៉ាល់ធី តើតើស ត្រេឌីង** ៣៤៤៩

២៤-៤-២០០៦ -លិខិតលេខ ១០៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល.អេច.អ អាស៊ាន អ៊ិនវេសមេន** ៣៤៥១

២៥-៤-២០០៦ -លិខិតលេខ ១១០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាល់ហ្វា អុហ្វសរ ឌ្រីលលីង (ខេមបូឌា) អិលធីឌី** ៣៤៥៣

២៥-៤-២០០៦ -លិខិតលេខ ១១០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាស៊ីម៉ា (ខេមបូឌា) ខូ អិលធីឌី** ៣៤៥៤

២៥-៤-២០០៦ -លិខិតលេខ ១១០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដីរេស** ៣៤៥៦

២៥-៤-២០០៦ -លិខិតលេខ ១១០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រាយវេត ត្រេឌីង ខូ អិលធីឌី** ៣៤៥៨

២៥-៤-២០០៦ -លិខិតលេខ ១១០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាវេសខេម** ៣៤៦០

២៥-៤-២០០៦ -លិខិតលេខ ១១១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្តាំរឡិច ហ្គហ្វ ខូ អិលធីឌី** ៣៤៦២

២៥-៤-២០០៦ -លិខិតលេខ ១១១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីល ឌីវេឡុបមេន** ៣៤៦៤

២៦-៤-២០០៦ -លិខិតលេខ ១១១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ព្រីមៀម គ្លូបិល (ខេមបូឌា)** ៣៤៦៦

២៦-៤-២០០៦ -លិខិតលេខ ១១១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **៩ ស្តារ តៃវើដាយ កាស៊ីណូ ហូថេល ហ្វូលឌីង** ៣៤៦៨

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក គីម កៅ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៧៣១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ហត្ថលេខា
ឈាង តាន់

៣រស.០៦០៥.២៥៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៦

/២៥

នស/រកត/០៥០៦.៧៤៣

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានៈ ឯកឧត្តម ឌុល គៀន ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.០៦០៥.៧៥៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៦*

លេខៈ ៧៣៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម ធិន ឃន ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពាល-០៦០៥-២៥៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦*

លេខ: ៤៣៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

នស/រកត/០៥០៦/៧៤៥

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្ដម **ឌុច ហេង** ជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា ២** : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

លេខៈ ៧៣៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

៣រល.០៦០៥.២៥៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៦

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/៧៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី៤ នីតិកាលទី៣នៃរដ្ឋសភា នាថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម **វង សូត** ជារដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជំនួសឯកឧត្តម **ញៀប ប៊ុនជិន** ដែលត្រូវផ្លាស់ចេញពីមុខតំណែង។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧ល.០៦០៥.២៥៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៦*

លេខៈ ៧៣៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណាឌ តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ....៥៧....អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្ម...

មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពី ព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិនា ឆ្នាំ ២០០៣ ស្តីពី ការត្រួតពិនិត្យភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ហៅកាត់ថា "សាយតេស "
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០០៦

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់នូវនីតិវិធី និងយន្តការក្នុងការគ្រប់គ្រងលើការនាំចេញ នាំចូល ការនាំចេញបន្ត និងការនាំមកពីសមុទ្រអន្តរជាតិ នូវសំណាកប្រភេទសត្វ និងរុក្ខជាតិព្រៃ អនុលោមតាមអនុ-៷.ㅜ.

សញ្ញា ស្តីពី ពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃកំពុងរងគ្រោះថ្នាក់ហៅកាត់ថា "**សាយតេស** (CITES)" ។

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់សំណាកនៃប្រភេទសត្វ និង រុក្ខជាតិព្រៃ ដែលមានចុះឈ្មោះក្នុងបញ្ជីឧបសម្ព័ន្ធ I, II និង III នៃអនុសញ្ញា ស្តីពី ពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃកំពុងរងគ្រោះថ្នាក់ "សាយតេស" ហើយដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

រូបវន្តបុគ្គល នីតិបុគ្គលដែលធ្វើសកម្មភាពនាំចេញ នាំចូល នាំចេញបន្ត និងនាំមកពីសមុទ្រអន្តរជាតិ ក្នុងគោលដៅធ្វើពាណិជ្ជកម្មអន្តរជាតិលើសំណាកនៃប្រភេទដូចមានចុះក្នុងបញ្ជីឧបសម្ព័ន្ធសាយតេសត្រូវអនុវត្តតាមវិធានដូចមានចែងក្នុងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។

នីតិវិធីផ្សេងទៀតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលអនុវត្តចំពោះការធ្វើពាណិជ្ជកម្មអន្តរជាតិលើទំនិញទូទៅ មិនត្រូវបានអនុញ្ញាតឱ្យប្រើជំនួសនូវតម្រូវការនៃវិធានទាំងឡាយដូចមានចែងក្នុងអនុក្រឹត្យនេះសម្រាប់ការនាំចេញ នាំចូល នាំចេញបន្ត និងការនាំមកពីសមុទ្រអន្តរជាតិនូវសំណាកប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលបានចុះក្នុងបញ្ជីឧបសម្ព័ន្ធសាយតេសឡើយ ។

**មាត្រា ៣.-**

លទ្ធផលនៃការធ្វើវិសោធនកម្មបញ្ជីឧបសម្ព័ន្ធ I, II និង III នៃអនុសញ្ញាសាយតេស ត្រូវចូលជាធរមានដូចគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមកាលបរិច្ឆេទដែលប្រភេទសត្វ ឬរុក្ខជាតិព្រៃនោះបានចូលជាធរមានអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញាសាយតេស ។

រាល់សំណើសុំធ្វើវិសោធនកម្មបញ្ជីឧបសម្ព័ន្ធនៃអនុសញ្ញាសាយតេស ត្រូវមានការពិគ្រោះយោបល់ ជាមួយសមត្ថកិច្ចគ្រប់គ្រងសាយតេស សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជា និងក្រសួងបរិស្ថាន ចំពោះពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

រាជរដ្ឋាភិបាល អាចអនុវត្តបណ្តាអនុសាសន៍នៅក្នុងសេចក្តីសម្រេចចិត្ត និងសេចក្តីសម្រេចនានារបស់អង្គសន្និបាតប្រទេសជាសមាជិកនៃអនុសញ្ញាសាយតេស ដែលមានសង្គតិភាពទៅនឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់អនុក្រឹត្យនេះត្រូវបានកំណត់ដូចក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ។ល។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង និងសមត្ថកិច្ចវិទ្យាសាស្ត្រ សាយតេសកម្ពុជា

**មាត្រា ៥.-**

បង្កើតសមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា ចំណុះក្រោមក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។ សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា មានទីចាត់ការនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**មាត្រា ៦.-**

បង្កើតសមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជាចំនួនបី(៣)ដែលមានទីចាត់ការដូចខាងក្រោម:

ក- រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលបន្ទុកជាសមត្ថកិច្ចវិទ្យាសាស្ត្រ សាយតេសកម្ពុជា សម្រាប់ធនធានសត្វ និងរុក្ខជាតិព្រៃ បន្ថែមពីលើភារកិច្ចបច្ចុប្បន្ន។

ខ- នាយកដ្ឋានជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកជាសមត្ថកិច្ចវិទ្យាសាស្ត្រ សាយតេសកម្ពុជា សម្រាប់ធនធានជលផល បន្ថែមពីលើភារកិច្ចបច្ចុប្បន្ន។

គ-នាយកដ្ឋានការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានទទួលបន្ទុកជាសមត្ថកិច្ចវិទ្យាសាស្ត្រសាយតេស កម្ពុជាសម្រាប់ធនធាន សត្វ និងរុក្ខជាតិព្រៃនៅក្នុងតំបន់ការពារធម្មជាតិទាំង ២៣កន្លែង បន្ថែមពីលើ ភារកិច្ចបច្ចុប្បន្ន ។

**មាត្រា ៧.-**

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា មានតួនាទីសម្របសម្រួលជាមួយរដ្ឋបាលព្រៃឈើ នាយកដ្ឋាន ជលផល នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ និង ចេញឯកសារសាយតេសតាមតម្រូវការរបស់អនុសញ្ញាសាយតេស ក្នុងការនាំចេញ ការនាំចូល ការនាំចេញបន្ត និងការនាំមកពីសមុទ្រអន្តរជាតិនូវសំណាកប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធ សាយ តេស។

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា មានសិទ្ធិប្រើត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រាប់ការចេញឯកសារសាយតេស ការអនុវត្តអនុសញ្ញា និងអនុក្រឹត្យនេះ ស្របតាមមុខការរបស់ខ្លួន។

មានតែប្រធាន ឬមន្ត្រីដែលបានទទួលសិទ្ធិប្រទានពីប្រធានសមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជាប៉ុណ្ណោះ ដែលមានសិទ្ធិចុះហត្ថលេខាលើឯកសារសាយតេស ។៚

**មាត្រា ៨.-**

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា មានសមត្ថកិច្ចផ្តល់ ឬបដិសេធលើការស្នើសុំឯកសារសាយតេស តាមសំណើ និងអនុសាសន៍របស់សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជា សម្រាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិ លើសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស អនុលោមតាមតម្រូវការនៃ អនុសញ្ញាសាយតេស ច្បាប់ស្តីពីព្រៃឈើ ច្បាប់ពាក់ព័ន្ធផ្សេងទៀត និងអនុក្រឹត្យនេះ ។

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា មានសិទ្ធិដកហូត ព្យួរ ឬចាត់ទុកជាមោឃៈនូវឯកសារសាយ តេសណាមួយតាមសំណើរបស់សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជាក្នុងករណីឯកសារនោះ ឬ អ្នកកាន់កាប់ ឯកសារសាយតេសអសមត្ថភាព និងមិនអនុវត្តតាមនីតិវិធីដូចបានចែងក្នុងអនុក្រឹត្យនេះ ឬលិខិតបទដ្ឋានស្រប ច្បាប់ពាក់ព័ន្ធ។

**មាត្រា ៩.-**

សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជា មានសិទ្ធិកំណត់ការវាយតម្លៃផលមិនប៉ះពាល់ដល់ភាពរស់នៅ ក្នុងជម្រកធម្មជាតិនៃប្រភេទសត្វ ឬរុក្ខជាតិព្រៃក្នុងដែនសមត្ថកិច្ចសាមីតាមតម្រូវការរបស់អនុសញ្ញាសាយតេស និងការអនុវត្តអនុក្រឹត្យនេះ ។

## ជំពូកទី ៣
## ការធ្វើពាណិជ្ជកម្មអន្តរជាតិលើសំណាកនៃប្រភេទសត្វ និង រុក្ខជាតិព្រៃ ដែលចុះក្នុងបញ្ជីឧបសម្ព័ន្ធនៃអនុសញ្ញាសាយតេស

**មាត្រា ១០.-**

ការនាំចេញ ការនាំចូល ការនាំចេញបន្ត និងការនាំមកពីសមុទ្រអន្តរជាតិ នូវសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញាសាយតេស សម្រាប់គោលបំណងជាចម្បងធ្វើ ពាណិជ្ជកម្មអន្តរជាតិត្រូវបានហាមឃាត់ លើកលែងតែមានការអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។

ការនាំចេញ ការនាំចូល ការនាំចេញបន្ត និងការនាំមកពីសមុទ្រអន្តរជាតិ នូវសំណាកនៃប្រភេទសត្វ និង រុក្ខជាតិព្រៃដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញាសាយតេស ត្រូវអនុលោមតាមលក្ខខណ្ឌដូចខាង ក្រោម:

១- មិនបម្រើឱ្យគោលបំណងជាចម្បងធ្វើពាណិជ្ជកម្មអន្តរជាតិ ។

២- បានប្រព្រឹត្តស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

៣- មានលិខិតអនុញ្ញាតចេញដោយសមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា ដោយមានមូលដ្ឋានលើ៖

លក្ខខណ្ឌដូចខាងក្រោម:

ក- ការនាំចេញ:

- សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជា បានឱ្យយោបល់ថាការនាំចេញ នឹងមិនធ្វើឱ្យខូចខាតដល់ការរស់រានមានជីវិតនៃប្រភេទនោះ នៅក្នុងធម្មជាតិឡើយ
- សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា បានទទួលការបញ្ជាក់ថា:

 ១- ការនាំចូលនោះមិនសម្រាប់បម្រើឱ្យគោលបំណងជាចម្បងធ្វើពាណិជ្ជកម្មអន្តរជាតិឡើយ ។

 ២- ការបញ្ជាក់ពីសមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជាថា សំណាកត្រូវបានទទួល ឬ ប្រមូលកាន់កាប់ដោយស្របច្បាប់ ។

 ៣- សំណាករស់នីមួយៗមានការរៀបចំថែរក្សា និងផ្ទុកក្នុងមធ្យោបាយបញ្ជូនបានល្អ ដើម្បីកាត់បន្ថយ ភាពបង្ករបួស អំពើពិបាកព្យាបាល ឬធ្វើឱ្យខូចដល់សុខភាពសត្វ ។

ខ- ការនាំចូល:

- សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជា បានឱ្យយោបល់ថាការនាំចូល នឹងមិនធ្វើឱ្យខូចខាតដល់ការរស់រានមានជីវិតនៃប្រភេទនោះ នៅក្នុងធម្មជាតិឡើយ
- សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា បានទទួលការបញ្ជាក់ថា:

 ១- ការនាំចូលនោះមិនសម្រាប់បម្រើឱ្យគោលបំណងជាចម្បងធ្វើពាណិជ្ជកម្មអន្តរជាតិឡើយ ។

 ២- ការនាំចូលបានប្រព្រឹត្តស្របតាមបទប្បញ្ញត្តិរបស់អនុសញ្ញាសាយតេស ។

 ៣- សំណាករស់នីមួយៗមានការរៀបចំថែរក្សា និងផ្ទុកក្នុងមធ្យោបាយបញ្ជូនបានល្អ ដើម្បីកាត់បន្ថយ ភាពបង្ករបួស អំពើពិបាកព្យាបាល ឬធ្វើឱ្យខូចដល់សុខភាពសត្វ ។

គ- ការនាំចេញបន្ត:

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជាបានទទួលការបញ្ជាក់ថា:

 ១- សំណាកត្រូវបាននាំចូលស្របតាមច្បាប់ជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ។

 ២- សំណាករស់នីមួយៗមាន ការរៀបចំផ្ទុកក្នុងមធ្យោបាយបញ្ជូន និងថែរក្សាបានល្អ ដើម្បីកាត់បន្ថយភាពបង្ករបួស អំពើពិបាកព្យាបាល ឬធ្វើឱ្យខូចដល់សុខភាពសត្វ ។ ៚

៣- គោលបំណងនៃការនាំចូលសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃនោះ គឺមិនបម្រើឱ្យគោលបំណងជាចម្បងធ្វើពាណិជ្ជកម្មអន្តរជាតិឡើយ ។

ឃ- ការនាំមកពីសមុទ្រអន្តរជាតិ:

- សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជា បានឱ្យយោបល់ថាការនាំចូលសំណាកមកពីសមុទ្រអន្តរជាតិ នឹងមិនធ្វើឱ្យខូចខាតដល់ការរស់រានមានជីវិតនៃប្រភេទនោះនៅក្នុងធម្មជាតិឡើយ
- សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា បានទទួលការបញ្ជាក់ថា:

១- ការនាំចូលសំណាករស់មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីធ្វើជាទ្រុងផ្ទុក និងថែរក្សាបានល្អនូវសំណាកដែលត្រូវនាំចូលនោះ ។

២- សំណាកដែលនាំចូលនោះមិនមានការប្រើប្រាស់សម្រាប់គោលបំណងជាចម្បងធ្វើពាណិជ្ជកម្មអន្តរជាតិឡើយ ។

**មាត្រា ១១.-**

ការនាំចេញ ការនាំចូល ការនាំចេញបន្ត និង ការនាំមកពីសមុទ្រអន្តរជាតិ នូវសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធ II និង III នៃអនុសញ្ញាសាយតេសត្រូវមានលិខិតអនុញ្ញាត និងឯកសារសាយតេសដែលផ្តល់ដោយសមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា និងត្រូវគោរពតាមនីតិវិធីនៃប្រតិបត្តិការ នាំចេញ នាំចូល នាំចេញបន្ត និងនាំមកពីសមុទ្រអន្តរជាតិ ស្របតាមតម្រូវការរបស់អនុសញ្ញាសាយតេស ។

**មាត្រា ១២.-**

នីតិវិធីនៃការចេញឯកសារសាយតេស និងប្រតិបត្តិការសម្រាប់ការនាំចេញ នាំចូល នាំចេញបន្ត និងការនាំមកពីសមុទ្រអន្តរជាតិនូវសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធសាយតេសត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ១៣.-**

បុគ្គលដែលស្នើសុំឯកសារសាយតេសត្រូវបង់ថ្លៃសេវាកម្មលើពាក្យស្នើសុំ ជូនសមត្ថកិច្ចគ្រប់គ្រងសាយតេស ។

បុគ្គលដែលស្នើសុំនាំចេញសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ដូចមានចុះក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ត្រូវបង់ថ្លៃសួយសារសត្វព្រៃ ថ្លៃអភិរក្សសត្វព្រៃ ថ្លៃសួយសារ និងថ្លៃបុព្វលាភរុក្ខជាតិព្រៃ និងពន្ធផ្សេងទៀត ជូនរដ្ឋតាមការកំណត់ ស្របតាមច្បាប់ស្តីពីព្រៃឈើ និង ច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

## ជំពូកទី ៤

## ការគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលចុះក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស មានប្រភពកំណើតពីកសិដ្ឋានបង្កាត់ពូជសត្វ ឬធ្វើពហុកម្មរុក្ខជាតិដោយសិប្បនិម្មិត

**មាត្រា ១៤.-**

ការនាំចេញសំណាកប្រភេទសត្វនិងរុក្ខជាតិព្រៃក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញាសាយតេសដែលមានប្រភពចេញពីកសិដ្ឋានដែលបានចុះបញ្ជីស្របច្បាប់ ម្ចាស់កសិដ្ឋានត្រូវដាក់ស្លាកសញ្ញាសម្គាល់ដោយឡែក និងជាអចិន្ត្រៃយ៍លើសំណាកនៃប្រភេទនីមួយៗស្របតាមវិធានកំណត់ ។

**មាត្រា ១៥.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កើតកសិដ្ឋានចិញ្ចឹម បង្កាត់ពូជសត្វ ឬធ្វើពហុកម្មរុក្ខជាតិព្រៃ ដើម្បីនាំចេញសំណាកដែលមានក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម:

១- ការបង្កើតកសិដ្ឋាន ត្រូវបានអនុញ្ញាតដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទតាមសំណើរបស់រដ្ឋបាលព្រៃឈើ ឬសំណើរបស់នាយកដ្ឋានជលផលចំពោះធនធានជលផល ។

២- ត្រូវចុះបញ្ជីកសិដ្ឋាន និងបញ្ជីសំណាកសត្វ ឬរុក្ខជាតិព្រៃនៅរដ្ឋបាលព្រៃឈើ ឬនៅនាយកដ្ឋានជលផល ចំពោះធនធានជលផល ។

៣- សកម្មភាពប្រតិបត្តិរបស់កសិដ្ឋាន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលព្រៃឈើ ឬនាយកដ្ឋានជលផលចំពោះធនធានជលផល និងត្រូវមានសង្គតិភាពជាមួយបទបញ្ញត្តិទាំងឡាយដែលបានកំណត់ក្នុងប្រកាសឱ្យបង្កើតកសិដ្ឋាននោះ។

បុគ្គលដែលកាន់កាប់កសិដ្ឋានក្នុងគោលបំណងជាចម្បងធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃក្នុងឧបសម្ព័ន្ធអនុសញ្ញាសាយតេស នៅមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវចុះបញ្ជីនៅរដ្ឋបាលព្រៃឈើ ឬនៅនាយកដ្ឋានជលផលចំពោះធនធានជលផលក្នុងរយៈពេល ១២ខែ គិតចាប់ពីកាលបរិច្ឆេទដែលអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ១៦.-**

ម្ចាស់នៃកសិដ្ឋានចិញ្ចឹមសត្វ ឬធ្វើពហុកម្មរុក្ខជាតិព្រៃក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ត្រូវចុះបញ្ជីសំណាក និងដាក់ស្លាកសម្គាល់ប្រភេទសត្វឬរុក្ខជាតិព្រៃនោះ ដែលទទួលស្គាល់ដោយរដ្ឋបាលព្រៃឈើ ឬនាយកដ្ឋានជលផល រួមជាមួយតម្រូវការផ្សេងទៀត មុនពេលស្នើសុំឯកសារសាយតេសសម្រាប់នាំចេញ ទៅសមត្ថកិច្ចគ្រប់គ្រង [illegible]

សាយតេសកម្ពុជា ។

សមត្ថកិច្ចវិទ្យាសាស្ត្រសាយតេស អាចចេញវិញ្ញាបនប័ត្របញ្ជាក់ពូជសត្វព្រៃ ឬវិញ្ញាបនប័ត្រពហុកម្មរុក្ខជាតិព្រៃដោយសិប្បនិម្មិត្តនៃប្រភេទក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ដែលមានប្រភពចេញពីកសិដ្ឋានដែលបានចុះបញ្ជី និងមានប្រកាសបង្កើតកសិដ្ឋាន ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១៧.-**

អាចអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មអន្តរជាតិលើសំណាក ឬប្រភេទសត្វនិងរុក្ខជាតិព្រៃ ក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ជាមួយរដ្ឋដែលមិនមែនជាសមាជិកអនុសញ្ញានេះ និងបានទទួលស្គាល់ដោយលេខាធិការដ្ឋានសាយតេសអន្តរជាតិ និងជារដ្ឋដែលមានសមត្ថកិច្ចអាចបំពេញសមត្ថភាពការងារដូចសមត្ថកិច្ចសាយតេសកម្ពុជាដែរ ។

**មាត្រា ១៨.-**

បុគ្គលណាមួយមានបំណងធ្វើការនាំចូល ការនាំចេញ ឬការនាំចេញបន្ត នូវសំណាកប្រភេទសត្វ និងរុក្ខជាតិព្រៃក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ដែលជាទ្រព្យសម្បត្តិរបស់បុគ្គល និងគ្រួសារអាចធ្វើសេចក្តីប្រកាសពីទ្រព្យ សម្បត្តិផ្ទាល់ខ្លួន ឬស្នើសុំលិខិតយថាភូតចេញដោយសមត្ថកិច្ចគ្រប់គ្រងសាយតេស ។

## ជំពូកទី ៥
## នីតិវិធីនៃការត្រួតពិនិត្យ និង ការដោះស្រាយបទល្មើស

**មាត្រា ១៩.-**

អំពើល្មើសចំពោះអនុក្រឹត្យនេះ គឺសំដៅដល់បទល្មើសដែលបានប្រព្រឹត្តចំពោះសកម្មភាពពាណិជ្ជកម្មឆ្លងដែននូវសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃគ្រប់ប្រភេទ ដែលពាក់ព័ន្ធនឹងបញ្ជីឧបសម្ព័ន្ធសាយតេសដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

នីតិវិធីដោះស្រាយបទល្មើស ការកំណត់ប្រភេទនៃបទល្មើស និងទោសប្បញ្ញត្តិ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ស្តីពីព្រៃឈើ ឬ ច្បាប់ពាក់ព័ន្ធជាធរមាន ។

នីតិវិធីនៃការអនុវត្តអនុសញ្ញាសាយតេស និងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២០.-**

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា មានសមត្ថកិច្ចប្រចាំការត្រួតពិនិត្យសកម្មភាពពាណិជ្ជកម្មអន្តរជាតិលើសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃគ្រប់ប្រភេទ នៅកំពង់ផែ ឬត្រង់ច្រក នាំចេញ-នាំចូលអន្តរជាតិ ។

ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២១.-**

មន្ត្រីរដ្ឋបាលព្រៃឈើ និង មន្ត្រីនាយកដ្ឋានជលផល ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវបំពេញតួនាទីជាមន្ត្រីសាយតេស និងមានសមត្ថកិច្ចត្រួតពិនិត្យដោះស្រាយអំពើល្មើសចំពោះអនុក្រឹត្យនេះ ដោយអនុលោមតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត។

**មាត្រា ២២.-**

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជាត្រូវបញ្ជូនសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញាសាយតេសបន្ទាប់ពីបានចាប់រឹបអូស និងការពិគ្រោះយោបល់ជាមួយប្រទេសនាំចេញទៅប្រទេសនាំចេញនោះវិញ ឬដោះលែងទៅក្នុងជម្រកធម្មជាតិដែលសមស្របទៅនឹងលក្ខខណ្ឌជីវិតរស់នៅរបស់វា ឬត្រូវបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វ ឬរុក្ខជាតិព្រៃណាមួយ ដែលសមត្ថកិច្ចគ្រប់គ្រង និងសមត្ថកិច្ចវិទ្យាសាស្ត្រសាយតេសកម្ពុជាបានឯកភាពគ្នា។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ២៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ពាក់ព័ន្ធផ្សេងទៀតជាធរមាន។

ជនល្មើសត្រូវចេញសោហ៊ុយ ក្នុងការលើកដាក់ ដឹកជញ្ជូនវត្ថុតាង ឬ បញ្ជូនសំណាកទៅប្រទេសនាំចេញវិញ ឬដោះលែងទៅក្នុងជម្រកធម្មជាតិដែលសមស្របទៅនឹងលក្ខខណ្ឌជីវិតរស់នៅរបស់វា ឬត្រូវបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វ ឬរុក្ខជាតិព្រៃណាមួយ និងចំណាយផ្សេងទៀត ក្នុងដំណើរការអនុវត្តច្បាប់។

**មាត្រា ២៤.-**

វត្ថុតាងពិតប្រាកដនៃបទល្មើសដែលជាមូលដ្ឋានក្នុងការកំណត់ទណ្ឌកម្ម គឺសំដៅលើសំណាកនៃប្រភេទសត្វ ឬ រុក្ខជាតិព្រៃដែលមានក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ដែលស្តែងចេញពីសកម្មភាពល្មើសឆ្លងដែនជាក់ស្តែងក្នុងគោលដៅធ្វើពាណិជ្ជកម្មអន្តរជាតិ។ ស.រ.

**មាត្រា ២៥.-**

បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងអនុសញ្ញាសាយតេសមិនរាងចាលច្រើនលើក ក្រោយពីបានទទួលទណ្ឌកម្មតាមគ្រប់រូបភាព ដោយមិនអនុញ្ញាតឱ្យដំណើរការសកម្មភាពពាណិជ្ជកម្មអន្តរជាតិលើប្រភេទក្នុងបញ្ជីឧបសម្ព័ន្ធសាយតេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលពីបី(៣)ទៅប្រាំ(៥)ឆ្នាំ ទោះជាបុគ្គលនោះត្រូវទទួលទោសដូចបានកំណត់ក្នុងច្បាប់ស្តីពីព្រៃឈើ ឬច្បាប់ពាក់ព័ន្ធដែលស្ថិតនៅជាធរមានផ្សេងទៀតក៏ដោយ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ២៦.-**

រដ្ឋបាលព្រៃឈើ និងនាយកដ្ឋានជលផល ត្រូវកំណត់ការចុះបញ្ជីកាស្របច្បាប់នូវសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃក្នុងបញ្ជីឧបសម្ព័ន្ធសាយតេសដែលបានកាន់កាប់ធ្វើជាកម្មសិទ្ធដោយរូបវ័ន្តបុគ្គល ឬនីតិបុគ្គលស្របតាមការកំណត់ពេលវេលាដូចខាងក្រោម:

ក- ការកាន់កាប់សំណាកនៅមុនថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៧ ដែលអនុសញ្ញាសាយតេស បានចូលជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

ខ- ការកាន់កាប់សំណាកនៅមុនពេល និងក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន។

ការចុះបញ្ជីស្របច្បាប់នេះ មានរយៈពេល ២៤ ខែ គិតចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ២៧.-**

សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា អាចផ្តល់វិញ្ញាបនប័ត្របុរេ-អនុសញ្ញា សម្រាប់សំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស ដែលត្រូវបានបង្ហាញដោយបុគ្គលស្នើសុំថា ជាសំណាកដែលបានកាន់កាប់មុនអនុសញ្ញាចូលជាធរមាន។ សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា មានពេល ២៤ខែ សម្រាប់ផ្តល់វិញ្ញាបនប័ត្របុរេ-អនុសញ្ញាលើសំណាកនៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន ។

បុគ្គលស្នើសុំត្រូវមានឯកសារបញ្ជាក់ពីអាយុកាលរបស់សំណាកគិតចាប់ពីពេលប្រមូលយកពីព្រៃធម្មជាតិ មកកាន់កាប់ដំបូង ឬមានឯកសារនាំចូលពីពេលមុន ឬពេលទទួលកាន់កាប់ដំបូង។ N.T.



## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ២៨.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ល.ក.

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ២៩
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ......៥៧.........អនក្រ.បក ចុះថ្ងៃទី[illegible]ខែឧសភា ឆ្នាំ២០០៦
## ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិ លើប្រភេទសត្វ និងរុក្ខជាតិព្រៃកំពុងរងគ្រោះថ្នាក់
## ដកស្រង់ទាំងស្រុងចេញពី
## ឧបសម្ព័ន្ធទី I, II និង III នៃអនុសញ្ញាសាយតេស

1. Species included in these Appendices are referred to:

   a) by the name of the species; or
   b) as being all of the species included in a higher taxon or designated part thereof.

2. The abbreviation "spp." is used to denote all species of a higher taxon.

3. Other references to taxa higher than species are for the purposes of information or classification only. The common names included after the scientific names of families are for reference only. They are intended to indicate the species within the family concerned that are included in the Appendices. In most cases this is not all of the species within the family.

4. The following abbreviations are used for plant taxa below the level of species:

   a) "ssp." is used to denote subspecies; and
   b) "var(s)." is used to denote variety (varieties).

5. As none of the species or higher taxa of FLORA included in Appendix I is annotated to the effect that its hybrids shall be treated in accordance with the provisions of Article III of the Convention, this means that artificially propagated hybrids produced from one or more of these species or taxa may be traded with a certificate of artificial propagation, and that seeds and pollen (including pollinia), cut flowers, seedling or tissue cultures obtained *in vitro*, in solid or liquid media, transported in sterile containers of these hybrids are not subject to the provisions of the Convention.

6. The names of the countries in parentheses placed against the names of species in Appendix III are those of the Parties submitting these species for inclusion in this Appendix.

7. In accordance with Article I, paragraph (b), sub-paragraph (iii), of the Convention, the symbol (#) followed by a number placed against the name of a species or higher taxon included in Appendix II or III designates parts or derivatives which are specified in relation thereto for the purposes of the Convention as follows:

   #1 Designates all parts and derivatives, except:
      a) seeds, spores and pollen (including pollinia);
      b) seedling or tissue cultures obtained *in vitro*, in solid or liquid media, transported in sterile containers; and
      c) cut flowers of artificially propagated plants.

   #2 Designates all parts and derivatives, except:
      a) seeds and pollen;
      b) seedling or tissue cultures obtained *in vitro*, in solid or liquid media, transported in sterile containers;
      c) cut flowers of artificially propagated plants; and
      d) chemical derivatives and finished pharmaceutical products.

   #3 Designates whole and sliced roots and parts of roots, excluding manufactured parts or derivatives such as powders, pills, extracts, tonics, teas and confectionery.

International Environment House • Chemin des Anémones • CH-1219 Châtelaine, Geneva • Switzerland
Tel: +41 (22) 917 81 39/40 • Fax: +41 (22) 797 34 17 • Email: cites@unep.ch • Web: http://www.cites.org

| Appendices I | II | III |
|---|---|---|
| **FAUNA (ANIMALS)** | | |
| **PHYLUM CHORDATA** | | |
| **CLASS MAMMALIA (MAMMALS)** | | |
| MONOTREMATA | | |
| Tachyglossidae Echidnas, spiny anteaters | | |
| | *Zaglossus* spp. | |
| DASYUROMORPHIA | | |
| Dasyuridae Dunnarts | | |
| *Sminthopsis longicaudata*<br>*Sminthopsis psammophila* | | |
| Thylacinidae Tasmanian wolf, thylacine | | |
| *Thylacinus cynocephalus* (possibly extinct) | | |
| PERAMELEMORPHIA | | |
| Peramelidae Bandicoots | | |
| *Chaeropus ecaudatus* (possibly extinct)<br>*Macrotis lagotis*<br>*Macrotis leucura*<br>*Perameles bougainville* | | |
| DIPROTODONTIA | | |
| Phalangeridae Cuscuses | | |
| | *Phalanger orientalis*<br>*Spilocuscus maculatus* | |
| Vombatidae Northern hairy-nosed wombat | | |
| *Lasiorhinus krefftii* | | |
| Macropodidae Kangaroos, wallabies | | |
| | *Dendrolagus inustus*<br>*Dendrolagus ursinus* | |
| *Lagorchestes hirsutus*<br>*Lagostrophus fasciatus*<br>*Onychogalea fraenata*<br>*Onychogalea lunata* | | |
| Potoroidae Rat-kangaroos | | |
| *Bettongia* spp.<br>*Caloprymnus campestris* (possibly extinct) | | |
| SCANDENTIA | | |
| Tupaiidae Tree shrews | | |
| | Tupaiidae spp. | |
| CHIROPTERA | | |
| Phyllostomidae Broad-nosed bat | | |
| | | *Platyrrhinus lineatus* (Uruguay) |
| Pteropodidae Fruit bats, flying foxes | | |
| | *Acerodon* spp. (Except the species included in Appendix I) | |
| *Acerodon jubatus*<br>*Acerodon lucifer* (possibly extinct) | | |

| Appendices I | II | III |
| --- | --- | --- |
| | ***Pteropus*** **spp.** (Except the species included in Appendix I) | |
| ***Pteropus insularis***<br>***Pteropus mariannus***<br>***Pteropus molossinus***<br>***Pteropus phaeocephalus***<br>***Pteropus pilosus***<br>***Pteropus samoensis***<br>***Pteropus tonganus*** | | |
| PRIMATES Apes, monkeys | | |
| | **PRIMATES spp.** (Except the species included in Appendix I) | |
| Lemuridae Large lemurs | | |
| **Lemuridae spp.** | | |
| Megaladapidae Sportive lemurs | | |
| **Megaladapidae spp.** (possibly extinct) | | |
| Cheirogaleidae Dwarf lemurs | | |
| **Cheirogaleidae spp.** | | |
| Indridae Avahi, indris, sifakas, woolly lemurs | | |
| **Indridae spp.** | | |
| Daubentoniidae Aye-aye | | |
| ***Daubentonia madagascariensis*** | | |
| Callitrichidae Marmosets, tamarins | | |
| ***Callimico goeldii***<br>***Callithrix aurita***<br>***Callithrix flaviceps***<br>***Leontopithecus*** **spp.**<br>***Saguinus bicolor***<br>***Saguinus geoffroyi***<br>***Saguinus leucopus***<br>***Saguinus oedipus*** | | |
| Cebidae New World monkeys | | |
| ***Alouatta coibensis***<br>***Alouatta palliata***<br>***Alouatta pigra***<br>***Ateles geoffroyi frontatus***<br>***Ateles geoffroyi panamensis***<br>***Brachyteles arachnoides***<br>***Cacajao*** **spp.**<br>***Chiropotes albinasus***<br>***Lagothrix flavicauda***<br>***Saimiri oerstedii*** | | |
| Cercopithecidae Old World monkeys | | |
| ***Cercocebus galeritus galeritus***<br>***Cercopithecus diana***<br>***Macaca silenus***<br>***Mandrillus leucophaeus***<br>***Mandrillus sphinx***<br>***Nasalis concolor***<br>***Nasalis larvatus***<br>***Presbytis potenziani*** | | |

| Appendices | | |
|---|---|---|
| I | II | III |
| ***Procolobus pennantii kirkii***<br>***Procolobus rufomitratus***<br>***Pygathrix* spp.**<br>***Semnopithecus entellus***<br>***Trachypithecus geei***<br>***Trachypithecus pileatus*** | | |
| Hylobatidae Gibbons | | |
| **Hylobatidae spp.** | | |
| Hominidae Chimpanzees, gorilla, orang-utan | | |
| ***Gorilla gorilla***<br>***Pan* spp.**<br>***Pongo pygmaeus*** | | |
| XENARTHRA | | |
| Myrmecophagidae American anteaters | | |
| | *Myrmecophaga tridactyla* | *Tamandua mexicana* (Guatemala) |
| Bradypodidae Three-toed sloth | | |
| | *Bradypus variegatus* | |
| Megalonychidae Two-toed sloth | | |
| | | *Choloepus hoffmanni* (Costa Rica) |
| Dasypodidae Armadillos | | |
| ***Priodontes maximus*** | *Chaetophractus nationi* (A zero annual export quota has been established. All specimens shall be deemed to be specimens of species included in Appendix I and the trade in them shall be regulated accordingly) | *Cabassous centralis* (Costa Rica)<br>*Cabassous tatouay* (Uruguay) |
| PHOLIDOTA | | |
| Manidae Pangolins | | |
| | ***Manis* spp.** (A zero annual export quota has been established for *Manis crassicaudata*, *M. javanica* and *M. pentadactyla* for specimens removed from the wild and traded for primarily commercial purposes) | |
| LAGOMORPHA | | |
| Leporidae Hispid hare, volcano rabbit | | |
| ***Caprolagus hispidus***<br>***Romerolagus diazi*** | | |
| RODENTIA | | |
| Sciuridae Ground squirrels, tree squirrels | | |
| ***Cynomys mexicanus*** | | *Epixerus ebii* (Ghana)<br>*Marmota caudata* (India)<br>*Marmota himalayana* (India) |

| Appendices I | II | III |
|---|---|---|
| | ***Ratufa*** **spp.** | ***Sciurus deppei*** (Costa Rica) |
| Anomaluridae African flying squirrels | | |
| | | ***Anomalurus beecrofti*** (Ghana)<br>***Anomalurus derbianus*** (Ghana)<br>***Anomalurus pelii*** (Ghana)<br>***Idiurus macrotis*** (Ghana) |
| Muridae Mice, rats | | |
| ***Leporillus conditor***<br>***Pseudomys praeconis***<br>***Xeromys myoides***<br>***Zyzomys pedunculatus*** | | |
| Hystricidae Crested porcupine | | |
| | | ***Hystrix cristata*** (Ghana) |
| Erethizontidae New World porcupines | | |
| | | ***Sphiggurus mexicanus*** (Honduras)<br>***Sphiggurus spinosus*** (Uruguay) |
| Agoutidae Paca | | |
| | | ***Agouti paca*** (Honduras) |
| Dasyproctidae Agouti | | |
| | | ***Dasyprocta punctata*** (Honduras) |
| Chinchillidae Chinchillas | | |
| ***Chinchilla*** **spp.** (Specimens of the domesticated form are not subject to the provisions of the Convention) | | |
| CETACEA Dolphins, porpoises, whales | | |
| | CETACEA spp. (Except the species included in Appendix I. A zero annual export quota has been established for live specimens from the Black Sea population of *Tursiops truncatus* removed from the wild and traded for primarily commercial purposes) | |
| Platanistidae River dolphins | | |
| ***Lipotes vexillifer***<br>***Platanista*** **spp.** | | |
| Ziphiidae Beaked whales, bottle-nosed whales | | |
| ***Berardius*** **spp.**<br>***Hyperoodon*** **spp.** | | |
| Physeteridae Sperm whales | | |
| ***Physeter catodon*** | | |
| Delphinidae Marine dolphins | | |
| ***Sotalia*** **spp.**<br>***Sousa*** **spp.** | | |
| Phocoenidae Porpoises | | |
| ***Neophocaena phocaenoides***<br>***Phocoena sinus*** | | |
| Eschrichtiidae Grey whale | | |
| ***Eschrichtius robustus*** | | |

| Appendices | | |
|---|---|---|
| I | II | III |
| Balaenopteridae Humpback whale, rorquals | | |
| ***Balaenoptera acutorostrata*** (Except the population of West Greenland, which is included in Appendix II) | | |
| ***Balaenoptera bonaerensis*** | | |
| ***Balaenoptera borealis*** | | |
| ***Balaenoptera edeni*** | | |
| ***Balaenoptera musculus*** | | |
| ***Balaenoptera physalus*** | | |
| ***Megaptera novaeangliae*** | | |
| Balaenidae Bowhead whale, right whales | | |
| ***Balaena mysticetus*** | | |
| ***Eubalaena*** **spp.** | | |
| Neobalaenidae Pygmy right whale | | |
| ***Caperea marginata*** | | |
| CARNIVORA | | |
| Canidae Bush dog, foxes, wolves | | |
| | | ***Canis aureus*** (India) |
| ***Canis lupus*** (Only the populations of Bhutan, India, Nepal and Pakistan; all other populations are included in Appendix II) | | |
| | ***Canis lupus*** (Except the populations of Bhutan, India, Nepal and Pakistan, which are included in Appendix I) | |
| | ***Cerdocyon thous*** | |
| | ***Chrysocyon brachyurus*** | |
| | ***Cuon alpinus*** | |
| | ***Pseudalopex culpaeus*** | |
| | ***Pseudalopex griseus*** | |
| | ***Pseudalopex gymnocercus*** | |
| ***Speothos venaticus*** | | |
| | | ***Vulpes bengalensis*** (India) |
| | ***Vulpes cana*** | |
| | | ***Vulpes vulpes griffithi*** (India) |
| | | ***Vulpes vulpes montana*** (India) |
| | | ***Vulpes vulpes pusilla*** (India) |
| | ***Vulpes zerda*** | |
| Ursidae Bears, pandas | | |
| | **Ursidae spp.** (Except the species included in Appendix I) | |
| ***Ailuropoda melanoleuca*** | | |
| ***Ailurus fulgens*** | | |
| ***Helarctos malayanus*** | | |
| ***Melursus ursinus*** | | |
| ***Tremarctos ornatus*** | | |
| ***Ursus arctos*** (Only the populations of Bhutan, China, Mexico and Mongolia; all other populations are included in Appendix II) | | |

| Appendices I | II | III |
|---|---|---|
| *Ursus arctos isabellinus*<br>*Ursus thibetanus* | | |
| Procyonidae Coatis, kinkajou, olingos | | |
| | | *Bassaricyon gabbii* (Costa Rica)<br>*Bassariscus sumichrasti* (Costa Rica)<br>*Nasua narica* (Honduras)<br>*Nasua nasua solitaria* (Uruguay)<br>*Potos flavus* (Honduras) |
| Mustelidae Badgers, martens, weasels, etc. | | |
| Lutrinae Otters | | |
| *Aonyx congicus* (Only the populations of Cameroon and Nigeria; all other populations are included in Appendix II)<br>*Enhydra lutris nereis*<br>*Lontra felina*<br>*Lontra longicaudis*<br>*Lontra provocax*<br>*Lutra lutra*<br>*Pteronura brasiliensis* | **Lutrinae spp.** (Except the species included in Appendix I) | |
| Mellivorinae Honey badger | | |
| | | *Mellivora capensis* (Botswana, Ghana) |
| Mephitinae Hog-nosed skunk | | |
| | *Conepatus humboldtii* | |
| Mustelinae Grisons, martens, tayra, weasels | | |
| *Mustela nigripes* | | *Eira barbara* (Honduras)<br>*Galictis vittata* (Costa Rica)<br>*Martes flavigula* (India)<br>*Martes foina intermedia* (India)<br>*Martes gwatkinsii* (India)<br>*Mustela altaica* (India)<br>*Mustela erminea ferghanae* (India)<br>*Mustela kathiah* (India)<br>*Mustela sibirica* (India) |
| Viverridae Binturong, civets, falanouc, fossa, linsangs, otter-civet, palm civets | | |
| | *Cryptoprocta ferox*<br>*Cynogale bennettii*<br>*Eupleres goudotii*<br>*Fossa fossana*<br>*Hemigalus derbyanus*<br>*Prionodon linsang* | *Arctictis binturong* (India)<br>*Civettictis civetta* (Botswana)<br>*Paguma larvata* (India)<br>*Paradoxurus hermaphroditus* (India)<br>*Paradoxurus jerdoni* (India) |

| Appendices I | II | III |
|---|---|---|
| ***Prionodon pardicolor*** | | |
| | | ***Viverra civettina*** (India)<br>***Viverra zibetha*** (India)<br>***Viverricula indica*** (India) |
| Herpestidae Mongooses | | |
| | | ***Herpestes brachyurus fuscus*** (India)<br>***Herpestes edwardsii*** (India)<br>***Herpestes javanicus auropunctatus*** (India)<br>***Herpestes smithii*** (India)<br>***Herpestes urva*** (India)<br>***Herpestes vitticollis*** (India) |
| Hyaenidae Aardwolf | | |
| | | ***Proteles cristatus*** (Botswana) |
| Felidae Cats | | |
| | **Felidae spp.** (Except the species included in Appendix I. Specimens of the domesticated form are not subject to the provisions of the Convention) | |
| ៣២- ប្រភេទសត្វ និងរុក្ខ-ជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស (Wild Animals and Plants Species Listed in CITES Appendixes) | :សំដៅដល់សំណាកនៃប្រភេទសត្វ ឬ រុក្ខជាតិព្រៃកំពុងរងគ្រោះថ្នាក់ ដែលបានចុះក្នុងបញ្ជីឧបសម្ព័ន្ធ I, II និងIII នៃអនុសញ្ញាសាយតេស។ ចំពោះប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាស្ថិតនៅក្នុងជម្រកធម្មជាតិ ឬកំពុងចិញ្ចឹមបង្កាត់ពូជស្ថិតក្នុងមជ្ឈដ្ឋានដែលមានការត្រួតពិនិត្យពីមនុស្ស ឬដែលមានប្រវត្តិចាប់ ប្រមូលយកពីព្រៃធម្មជាតិក៏ដោយ និងដែលបានចាត់ថ្នាក់នៅក្រោមច្បាប់ ស្តីពី ព្រៃឈើ ឬលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធត្រូវមានសុខដុមនីយកម្ម (Harmonization) ជាមួយបញ្ជីឧបសម្ព័ន្ធសាយ-តេស។ មិនត្រូវបានរាប់បញ្ចូលក្រោមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬអនុសញ្ញាសាយតេសឡើយចំពោះសត្វព្រៃ ឬរុក្ខជាតិព្រៃទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលគ្មានកំណត់ក្នុងបញ្ជីឧបសម្ព័ន្ធសាយតេស។ |

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៥៤...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង
## នៃក្រសួងធនធានទឹក និងឧតុនិយម

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម ។ ./.

**មាត្រា ២.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័នក្រសួង និង សហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/ស.រ.

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា**
**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**លឹម គានហោ**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់ វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការ បង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ១៣២០ អយក.ឧស ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦

## ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍** " Institute of Management and Development " ហៅកាត់ជាភាសាខ្មែរ " **វ.គ.អ** ". និងហៅកាត់ជាភាសាអង់គ្លេស **I.M.D** ។

**មាត្រា ២ :** វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានទីតាំងស្ថិតនៅ ភូមិពាលញែក២ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស នៅទីរួមខេត្តពោធិ៍សាត់ និងស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ និងបរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ ជាមធ្យម។ ក្នុងរយៈពេលបីខែ បន្ទាប់ពីថ្ងៃចាប់ដំណើរការ វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានមហាវិទ្យាល័យចំនួន ០៤ :

- មហាវិទ្យាល័យភាសាបរទេស
- មហាវិទ្យាល័យគ្រប់គ្រង
- មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥ :** វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន និងមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៧ :** វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។

**មាត្រា ៨ :** នាយកនៃវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ មានភារកិច្ចទទួលខុសត្រូវ នៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ធានាឱ្យបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៩ :** និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ១០ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថានគ្រប់គ្រង និងអភិវឌ្ឍន៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តពោធិ៍សាត់
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ..៣៦៨...អនក្រ-បក

# អនុក្រឹត្យ

# ស្តីពី

# ការតែងតាំងបន្ថែមគណៈគ្រប់គ្រង ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦ ស្តីពីការប្រែក្លាយពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ទៅជាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងបន្ថែមគណៈគ្រប់គ្រងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដែលមានព្រះនាម និង នាមដូចតទៅ :

១ - ព្រះទេពសត្ថា **ឃី សុវណ្ណរតនា** ជាសាកលវិទ្យាធិការរង នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២ - លោក **ហ៊ឹម យ៉ាន** ជាសាកលវិទ្យាធិការរង នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

| | | |
|---|---|---|
| ៣- ព្រះមហា | **យ៉ន សេងយៀត** | ជាសាកលវិទ្យាធិការរង នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ |
| ៤ - ព្រះមហា | **និន រិទ្ធិ** | ជាព្រឹទ្ធបុរស នៃពុទ្ធិកមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងព័ត៌មានវិទ្យា |
| ៥ - ព្រះមហា | **សាន សម្ពស្ស** | ជាព្រឹទ្ធបុរស នៃពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស |
| ៦ - លោក | **រឿង យ៉ុន** | ជាព្រឹទ្ធបុរស នៃពុទ្ធិកមហាវិទ្យាល័យទស្សនវិជ្ជា និងសាសនា |
| ៧ - លោក | **នួច ណារ៉ា** | ជាព្រឹទ្ធបុរស នៃពុទ្ធិកមហាវិទ្យាល័យអក្សរសាស្ត្រ ។ |

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០២រូប នៅខេត្តកោះកុង ដូចមានរាយនាមខាងក្រោម :

១- លោក **សោម សុធីរ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាលស្រុកស្រែអំបិល ឱ្យទៅជាអភិបាលស្រុកកោះកុង

២- លោក **ម៉ុន លើុត** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ពីអភិបាលស្រុកកោះកុង ឱ្យទៅជាអភិបាលស្រុកស្រែអំបិល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៦*

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការសម្រួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្ដូរក្របខ័ណ្ឌ ឋានន្តរសក្ដិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានសម្រួលភារកិច្ចលោក **មួរ គីមសាន** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៦ ពីអគ្គនាយករងបច្ចេកទេស នៃអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ ឱ្យទៅ

បម្រើការងារនៅក្របខណ្ឌដើម ជាអនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តពោធិសាត់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល :***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៣*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ៣៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **អ៊ុំ ពិសី** ជាទីប្រឹក្សាបច្ចេកទេសក្រសួងបរិស្ថាន មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៧៣ . អនក្រ . បក

## អនុក្រឹត្យ

## ស្តីពី

## ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ផ្លាស់លោកស្រី **ម៉ៃ សុន្ទរិន្ទ** បច្ចុប្បន្នអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ វិលចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៧២....អនក្រ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះដោះស្រាយ និង សម្របសម្រួលករណីក្រុមហ៊ុន អភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន តាមខ្លឹមសារនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល

~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
~~~~~

# សម្រេច

**ប្រការ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះដោះស្រាយ និង សម្របសម្រួលករណីក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន តាមខ្លឹមសារនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២-តំណាងក្រសួងការពារជាតិ | អនុប្រធាន |
| ៣-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤-តំណាងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៥-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៧-តំណាងក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |
| ៨-តំណាងអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |

**ប្រការ២** : គណៈកម្មការនេះ មានភារកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលពាក់ពន្ធ័ ចុះដោះស្រាយ និងសម្របសម្រួលជាក់ស្តែងដល់មូលដ្ឋានតាមខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ៤០១ សជណ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ពាក់ពន្ធ័ករណីដីសម្បទានចំនួន១២.៥០៦ហិកតា របស់ក្រុមហ៊ុនអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន ស្ថិតនៅភូមិត្រែងត្រយឹង ឃុំអូរ និង ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ រួចរាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣** : គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ៤** : អនុប្រធាន និងសមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំ និងចុះបំពេញភារកិច្ចតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង ស្ថាប័នពាក់ពន្ធ័ ព្រមទាំងសមាសភាព ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ៥
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

លេខ : ១៦៧ បទ.ប្រក

## ប្រកាស

## ស្តីពីការ បង្កើតក្រុមការងារ ដើម្បីរៀបចំអនុវត្ត ឱ្យមានប្រសិទ្ធភាព នៃគំរោងប្រាក់កម្ចី (JBIC)

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញលិខិតលេខ DAII/2005-375-1 ចុះថ្ងៃ ១៧ ខែ មីនា ឆ្នាំ ២០០៦ របស់ធនាគារសំរាប់សហប្រតិបត្តិការអន្តរជាតិ នៃប្រទេស ជប៉ុន ( JBIC ) ។
- បានឃើញលិខិតលេខ CP-P5/E-001 ចុះថ្ងៃ ១០ ខែ មេសា ឆ្នាំ ២០០៦ របស់ធនាគារសំរាប់សហប្រតិបត្តិការអន្តរជាតិ នៃប្រទេស ជប៉ុន ( JBIC ) ។
- បានឃើញលិខិតលេខ ២២៥ ទ.ក ច ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៦ របស់ទូរគមនាគមន៍កម្ពុជា ។
- យោងតាមការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារមួយរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-លោក | **ញឹក** | **កោសលវិទ្យា** | អគ្គនាយកទូរគមនាគមន៍កម្ពុជា | ប្រធាន |
| ២-លោក | **ម៉ូវ** | **ចរិយា** | អគ្គនាយករងទូរគមនាគមន៍កម្ពុជា | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣-លោក | អ៊ុច | រិទ្ធី | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន | សមាជិក |
| ៤-លោក | អ៊ឹម | វុត្ថា | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច និង គណនេយ្យ | សមាជិក |
| ៥-លោក | ប៉ាល់ | វុឌ្ឍិកា | អនុប្រធាននាយកដ្ឋានផែនការហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | តុល | ញ៉ាក់ | អនុប្រធានបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន | សមាជិក |
| ៧-លោក | រ៉ាង | ចាន់រិទ្ធី | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស | សមាជិក |
| ៩-លោក | ស៊ុន | ចំរើន | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១០-លោក | ហ៊ុន | ប្រុស | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១១-លោក | ហេង | សុខវិសេស | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១២-លោក | នុត | មុនីរត្ន | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១៣-លោក | ប៉ិត | សុត្ថារិទ្ធ | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១៤-អ្នកស្រី | ឱម | ចរិយា | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |

**១៥-មន្ត្រី ០១ រូប តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** សមាជិក

**ប្រការ ២** : ក្រុមការងារ ខាងលើនេះ មានភារកិច្ច :

-សហការការងារ ជាមួយធនាគារសំរាប់សហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន ( JBIC ) ដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាព នៃ គំរោងប្រាក់កម្ចី សំរាប់អនុវត្តគំរោងបណ្តាញឆ្អឹងខ្នងទូរគមនាគមន៍ មហាអនុតំបន់មេគង្គ " The Greater Mekong Telecommunications Backbone Network Project ( Cambodia Growth Corridor ) " ។

-ចប់ភារកិច្ច ត្រូវរាយការណ៍ពីលទ្ធផលការងារ ជូន ***ឯកឧត្តមរដ្ឋមន្ត្រី*** ។

**ប្រការ ៣** : ក្រុមការងារខាងលើ នេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ ***លោកប្រធាន*** និង អាចចាត់តាំងក្រុមការងារជំនាញផ្សេងទៀត តាមការងារចាំបាច់ ។

**ប្រការ ៤** : រាល់ប្រកាសទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គនាយកដ្ឋានរដ្ឋបាល ទូរគមនាគមន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អស់លោក ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្ត ឱ្យមានប្រសិទ្ធិខ្ពស់ តាមខ្លឹមសារ នៃ ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦

**រដ្ឋមន្ត្រី**

សូ ខុន

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៣១ ពណ.នគក

ភ្នំពេញថ្ងៃទី១២ ខែមេសា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អុកតូពូស (ខេមបូឌា) អ៊ិនវេសមេន គ្រុប**
**OCTOPUS ( CAMBODIA) INVESTMENT GROUP Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8623/06P** ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ម៉ូ ម៉ូលីណា** ប្រធានក្រុមប្រឹក្សាភិបាល
លោក VLADIMIR BOGNAT អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥០ ផ្លូវលេខ ៣៣៤ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសនាំចូលប្រេងឥន្ធនៈ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ ឱសថ-វិទ្យាស្ថានសុខភាពមនុស្ស
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជន...
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ...

CD ៩៧

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត រៀបចំសិល្បៈកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម-ពិសេសរោងចក្រផលិតគ្រឿងឧបភោគបរិភោគ ផលិតទឹកផ្លែឈើ ត្រីខកំប៉ុង

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចាម ប្រសិទ្ធ

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- បញ្ជីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៣៤ ពណ.ឧតក

ភ្នំពេញថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **(ខេមបូឌា ) ស៊ីហាវតា្ថ**

**( CAMBODIA ) SHIHAWATHA Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8619/06P** ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ខឹន លក្ខិណា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៧២៩ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះ ព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារត់ការងារជូនអតិថិជនទាំងក្នុងនិងក្រៅប្រទេស

-សេវាផ្សព្វផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៦៦០ ពណ.ឧតក

ភ្នំពេញថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភើឡា កាស៊ីណូ**
**PERLA CASINO Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co.,2877/06E ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **GUVEN SANLI ERASLAN** ប្រធានក្រុមប្រឹក្សាភិបាល
លោក **VEDAT ERBAS** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២១B ផ្លូវលេខ២៩៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនពលករខ្មែរក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និង កីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៦២ ពណ.នតក

ភ្នំពេញថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប៊ី វី ប៊ី អ៊ិនវេសមេន ខប**

**B V B INVESTMENT CORP.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8618/06P** ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ជួន ទិមុល** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ឯម សុគន្ធារី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៩២ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះ ព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកតំរូវផ្ញើរសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើរដ្ឋបាល ពាណិជ្ជកម្ម

-សេវារកការងារជូនពលករខ្មែរធ្វើការនៅក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.-ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤១០៦ ពណ.ឧតក

ភ្នំពេញថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **រស្មី មហាសម្បត្តិ**
**REASMEY MOHASAMBATH Co.,Ltd**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8620/06P ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក **ហេង ស៊ុំ**
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិព្រែកជីសាក់ ក្រុមទី១ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងតែងតាំង...
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់-សិក្សាគំរោងប្លង់គ្រប់ប្រភេទ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.-ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៧៤ ពណ.នតក

ភ្នំពេញថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន **Singapore Offshore Petroleum Services Pte. Ltd.** ត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សូបស៍ (ខេមបូឌា) អិលធីឌី**

**SOPS ( CAMBODIA ) LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2879/06E** ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក CHUA ENG BOON " តតីយជន "

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ១២៤ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ធ្វើអាជីវកម្ម: ចំណតនាវា កំពង់ផែ សំណង់លយទៅក្នុងទឹក ឃ្លាំងស្តុកទំនិញ ម្ចាស់នាវា អ្នកសាងសង់នាវា វិស្វករ ម៉ាស៊ីនបូម ម្ចាស់នាវាសណ្តោង អ្នកចាត់ចែងផែ អ្នកចាត់ចែងឃ្លាំង ភ្នាក់ងារកំរៃជើងសារ និងពាណិជ្ជកម្មផ្សេងៗទៀតដែលជួយសំរួលក្នុងការប្រតិបត្តិនូវអាជីវកម្មខាងលើ

-ធ្វើអាជីវកម្ម: ផ្តល់ចំណតនាវាចត នាវាចាកចេញ សំអាត និងគ្រឿងជំនួយផ្សេងៗ ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមនាវាដែលប្រតិបត្តិ និងគ្រប់គ្រង

-ផ្តល់នូវសេវាកម្មគ្រប់ប្រភេទ និងប្រតិបត្តិដូចជាអន្តរការីសំរាប់ម្ចាស់ដើម ក្នុងការលក់ទិញ ជួលទំនិញរបស់ប្រើប្រាស់ ប្រដាប់ប្រដារ គ្រឿងចក្រ និងសេវាកម្មទាក់ទងនឹងសកម្មភាពបូមប្រេង ឬ រ៉ែ

-អាជីវកម្ម [illegible] នាំចេញ នាំចូល ឬជាឈ្មួញទំនិញគ្រប់ប្រភេទ

-សេវាពិគ្រោះយោបល់លើ [illegible] បរិញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយ [illegible]

-បោះពុម្ពផ្សាយ [illegible]

-ផលិតខ្សែភាពយន្ត វីដេអូ CD -មហោស្រព

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន ម៉ាស្សា រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦០៧៥ ពណ.នគក

ភ្នំពេញថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ីមភៀរៀល ស៊ីឃ្យូរីធី សឺវីស**
**IMPERIAL SECURITY SERVICE Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8626/06P ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ហាន ស្រ៊ាង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៨៩ F ផ្លូវម៉ាស៊ីនទឹក សង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ធ្វើអាជីវកម្ម: សេវាកម្មសន្តិសុខឯកជន ក្នុងក្របខ័ណ្ឌរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងការពារសុវត្ថិភាពជូនដល់វិនិយោគិន ពាណិជ្ជករ រោងចក្រ សហគ្រាស ឃ្លាំង..។ល។

-ប្រព័ន្ធការពារដោយអេឡិចត្រូនិច-ការពារអគ្គីភ័យ

-ត្រួតពិនិត្យយាមកាម-ត្រួតពិនិត្យដោយទូរបញ្ជា

-និងជាទូទៅរាល់សេវា និងការផ្គត់ផ្គង់នូវឧបករណ៍សំភារៈសំរាប់ការងារការពារ បំណងល្អ និងសាមញ្ញ

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរ័ណ អាហរ័ណកម្មទំនិញគ្រប់ប្រភេទ ពិសេសលក់បរិក្ខារអេឡិចត្រូនិចសំរាប់ការពារសន្តិសុខក្នុងលំនៅដ្ឋាន និងសំភារៈការពារ មធ្យោបាយដឹកជញ្ជូន

